+855 (0)17774864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សា-សាបាសាក់ SA SA BASSAC

# ពន្លឺនៃព្រះនេត្រព្រះ

## ដោយ  ថន សុខ

នៅក្នុងពិព័រណ៍ *ពន្លឺនៃព្រះនេត្រព្រះ* ថន សុខ បង្កើតស្នាដៃចម្លាក់និងការតម្លើងដើម្បីចោទសួរជុំវិញទម្លាប់នៃការប្រគេនបច្ច័យ (លុយ) នៅប្រទេសកម្ពុជា ព្រមទាំងទាញនូវចំណងទាក់ទងរវាងតួនាទីរបស់ព្រះសង្ឃ និងសិល្បករ។

នៅប្រទេសកម្ពុជា ព្រះពុទ្ធសាសនាគឺស្ថិតនៅជាមួយគ្នានឹងជំនឿតាមដូនតា និងព្រហ្មញ្ញសាសនា។ ជាយូរមកហើយទាំងព្រះសង្ឃ និងសិល្បករ គឺមានមានតួនាទីពិសេសមួយក្នុងការផ្ទេរនូវវប្បធម៌ និងគុណតម្លៃខ្មែរ។ ធម៌វិន័យបានផ្តល់នូវគំរូរស់នៅប្រកបដោយអាកប្បកិរិយាដ៏គួរឲ្យសរសើររបស់ពុទ្ធសាសនិក រីឯការងារសិល្បៈវិញ ត្រូវបានគេយល់ថាប្រកបដោយចក្ខុវិស័យ និងមានផ្សារភ្ជាប់ខាងវិញ្ញាណ។

ទោះបីព្រះសង្ឃមួយចំនួនសច្ចារបួសជារៀងរហូត ក៏ការបួសនៅប្រទេសកម្ពុជាត្រូវបានគេយល់តាមទម្លាប់ថា ជាសិទ្ធិឆ្លងកាត់មួយដែលក្នុងនោះយុវជនត្រូវលះបង់មួយរយៈពេលបណ្តោះអាសន្ន ដើម្បីសន្សំបុណ្យជូនឪពុកម្តាយ។ មានការផ្លាស់ប្តូរមួយអន្លើក្នុងទម្លាប់ប្រគេនទេយ្យទាន ដោយគ្រហស្ថជំនួសចង្ហាន់ជាមួយនឹងបច្ច័យទៅវិញ ដែលទង្វើនេះទទួលការរិះគន់ថាអាចឱ្យសង្ឃបណ្តោយខ្លួន រួមទាំងការកាន់បច្ច័យផងដែរ។ យុវជនជាច្រើនឥឡូវអាចទុកការបួសជាឱកាសដើម្បីរួចផុតពីភាពក្រីក្រ ផ្លាស់ប្តូរទីលំនៅមកកាន់ទីក្រុង ចូលរួមការសិក្សាបែបអាណាចក្រ ហើយត្រូវបានឃើញថាមានប្រលូកក្នុងជីវិតជាគ្រហស្ថមុននឹងសឹក។ តែទោះជាយ៉ាងណា ទេយ្យទាននៅតែជាការអនុវត្តដ៏សំខាន់ និងជានិមិត្តសញ្ញានៃ*ព្រះសង្ឃ* ឬសហគមន៍ពុទ្ធសាសនា និងផ្តល់នូវឱកាសឱ្យអ្នកធ្វើទានសន្សំបុណ្យសម្រាប់ជាតិថ្មី។

ថន សុខ បានសាកល្បងទម្រង់នៃការបួសដើម្បីឱកាស ដោយបានបម្រើខ្លួនបីខែជាជំនួយការលោកនេន។ ក្នុងកំឡុងពេលនោះ គាត់ទទួលបានឱកាសមួយដែលគាត់ចាត់ទុកថាជាឱកាសដែលរិតតែមានអំណោយផល គឺក្លាយជាសិល្បករតាមរយៈការបណ្តុះបណ្តាលនៅវិទ្យាស្ថានរៃយំនៅភ្នំពេញ។ ចាប់តាំងពីរៀនចប់នៅឆ្នាំ២០០៥មក ការងារសិល្បៈរបស់គាត់គឺអង្កេតលើសម្ភារៈ និងទម្លាប់នៃជំនឿនៅកម្ពុជា។

នៅក្នុងពិព័រណ៍ *ពន្លឺនៃព្រះនេត្រព្រះ* សិល្បកររៀបចេញនូវដំណើររឿងទេយ្យទាននៅក្នុងបរិវេណវិចិត្រសាល។ *មានទៅមានមក ១* និង *២* (២០១២) កែច្នៃឡើងវិញនូវសម្ភារៈ និងទម្រង់ដែលបានប្រើនៅក្នុងការផ្លាស់ប្តូរ រវាងព្រះសង្ឃនិងគ្រហស្ថ។ កន្លែងដាក់តម្កល់ទេយ្យទានទាំងពីរត្រូវបានមើលពីលើដោយពន្លឺនិម្មិត្ត ដែលទាក់ទងនឹងញាណដឹងរបស់ព្រះ សម្រាប់រំលឹកថាចេតនា ដែលជាប្រភពនៃអំពើល្អ ឬអាក្រក់ ដែលយើងមើលមិនឃើញ «អាចត្រូវបានមើលឃើញ» តាមរយៈពន្លឺនិម្មិត្តនេះ។

*មានទៅមានមក ១* ផ្តោតលើទេយ្យទានដែលប្រគេនជូនវត្ត។ ពន្លឺធពណ្ណរង្សីជះបំភ្លឺទៅទិសខាងកើតទៅលើវាលភ្នំខ្សាច់ទាបៗ តំណាងឱ្យភ្នំព្រះសុមេរុ ដែលជាផ្ចិតរបស់ពិភពហិណ្ឌូតាមរឿងទេវកថា។ ភ្នំខ្សាច់ទាំងនេះត្រូវបានពូននៅក្រៅវត្ត កំឡុងពេលមានបុណ្យទានធំៗរបស់ខ្មែរ។ បច្ច័យនិងទេយ្យទានផ្សេងៗត្រូវបានស៊កចូលក្នុងភ្នំខ្សាច់នេះ ដើម្បីឱ្យអ្នកធ្វើទាននោះរួចផុតពីបាប ហើយអាចសុំឱ្យការបន់ស្រន់បានសម្រេច។ *មានទៅមានមក ២* ពិនិត្យលើទេយ្យទានដែលប្រគេនដល់បុគ្គលជាសង្ឃ។ អំពូលពងមាន់មួយត្រូវបានចងសំយ៉ុងចុះពីពិតាននៅចំកណ្តាលរង្វង់ឫស្សី ហើយមាន«កាំរស្មី»ធ្វើពីខ្សែអំបោះពណ៌ក្រហមប្រាល(ដែលព្រះសង្ឃចងនឹងកដៃរបស់គ្រហស្ថ ទុកជាការឱ្យពរទូទៅ) ភ្ជាប់ទៅនឹងមាត់បាត្រលោកចំនួន៨។ ដោយមានលក្ខណៈលេងសើចផង សិល្បករសុំឱ្យទស្សនិកជនសម្តែងជាការប្រគេនទេយ្យទាន ទៅតាមចេតនានិងជំនឿរបស់គេ ដើម្បីឱ្យគេបានបុណ្យពីការគាំទ្រដល់សិល្បករ។

# The Halo of The Omnipresent Eye

## Than Sok

In *The Halo of the Omnipresent Eye*, Than Sok's interactive sculpture and installation provoke questions around the practice of monetary almsgiving in Cambodia while drawing connections between the roles of monastics and artists.

In Cambodia, where Buddhism co-exists alongside pre-Buddhist animism and Brahman practices, both monks and artists have long occupied a unique position in the transmission of Khmer culture and values; monastic discipline has provided a living model of the most meritorious Buddhist behavior, while artistic practice has been regarded as visionary and with spiritual associations.

Although some monks commit to permanent vows, monkhood in Cambodia is traditionally considered a right of passage in which young males are expected to serve temporary terms intended as merit-building activities for parents. Due in part to a shift in almsgiving practices in which laity replace food with cash offerings - a practice antagonistic to precepts meant to prevent monks from indulgences including the handling of money - many young men can now consider monkhood as an opportunity to escape poverty, relocate to urban centers, participate in secular education, and are seen as participating in laic life before disrobing. Still, alms remain a central practice and symbol of the *sangha*, or Buddhist community, and provide the opportunity for givers to earn merit for a better rebirth.

Than Sok deliberated the monkhood-for-opportunity model, and served three months as a novice assistant, during which time he was offered what he considered a more favorable opportunity: to become an artist through the offering of the Reyum Art School in Phnom Penh. Since graduating in 2005, his artistic practice has investigated the materials and rituals of spiritual practices in his country.

*The Halo of the Omnipresent Eye* stages the artist's own alms scenarios in the gallery. *To Give Is To Receive I and II* (2012) reconfigure materials and forms used in exchanges between monks and laity. The pair of alms stations are presided over by representational halos associated with divine knowing – a reminder that intention, the source of good or bad action, which is invisible, is "visible" via its karmic effect.

*To Give Is To Receive I* concentrates on alms made to the temple. A colorful LED moiré light glows in the eastward direction onto a field of humble sand mounds – forms representing Mount Meru, the mythical axis of the Hindu world - which are built outside temples during major Khmer ceremonies. Money and other paraphernalia are slid into the sand mountain for which the person is released from sins and can request prayers answered. *To Give Is To Receive II* focuses on alms made to the individual monk. Suspended from the ceiling, a sole light bulb hangs in the center of bamboo hoop; its "rays" are made from the bright red cotton string, which monks tie to the wrists of laity as a general blessing, and connect to a ring of eight *bat lok*, or alms bowls. Playfully, the artist asks viewers to perform almsgiving, for which they will, by level of intention and belief, receive merit from supporting the artist.

# ពន្លឺនៃព្រះនេត្រព្រះ
## ដោយ ថន សុខ

# The Halo of The Omnipresent Eye
## Than Sok

27 January – 26 February 2012



Installation view, *The Halo of The Omnipresent Eye*, 2012

**អំពីសិល្បករ**
ថន សុខ (កើតនៅឆ្នាំ១៩៨៤ ខេត្តតាកែវ) អង្កេតលើជំនឿ សម្ភារៈ និងក្បួនសាសនា និងផ្លូវវិញ្ញាណ តាមរយៈចម្លាក់ ការតម្លើង វីដេអូ និងការសម្តែង។ សុខ រៀនចប់ពីវិទ្យាស្ថានរ៉េយំនៅឆ្នាំ២០០៥ និងបញ្ចប់សិក្ខាសាលារបស់រ៉េយំនៅឆ្នាំ២០០៧ ហើយបច្ចុប្បន្ននេះ កំពុងសិក្សាផ្នែកស្ថាបត្យកម្ម។ *ពន្លឺនៃព្រះនេត្រព្រះ* ជាពិព័រណ៍ទោលលើកទី២របស់គាត់ បន្ទាប់ពី *សោកនាដកម្ម* នៅបុប្ផាណា ភ្នំពេញ (២០០៩)។ ពិព័រណ៍ជាក្រុមរួមមាន *តាំងពីដើមមកដល់បច្ចុប្បន្ន* នៅវិចិត្រសាល ១០ Chancery Lane នៅទីក្រុងហុងកុង (២០០៩) និង *វីដេអូៈ សិល្បៈនិងប្រវត្តិសាស្ត្រ* សារមន្ទីរសិល្បៈសិង្ហបុរី (២០១១)។ សុខ ជាសិល្បករដែលធ្លាប់ស្នាក់នៅ Tokyo Wonder Site, Aoyama (២០០៥) និងនៅ S-AIR Sapporo (២០១១)។ ស្នាដៃរបស់គាត់ត្រូវបានប្រមូលទុកដោយសារមន្ទីរសិល្បៈសិង្ហបុរី។

**About the Artist**
Than Sok (born 1984, Takeo) investigates religious and spiritual beliefs, materials, and rituals through sculpture, installation, video and performance. Than graduated from Reyum Art School (2005), Reyum Workshop (2007) and is currently studying architecture. Select exhibitions include *Tragedy*, Bophana, Phnom Penh (2009), *Forever Until Now*, 10 Chancery Lane Gallery, Hong Kong (2009) and *Video: An Art, A History*, Singapore Art Museum (2011). Than was a resident at Tokyo Wonder Site (2005) and S-AIR, Sapporo (2011). His work is collected by the Singapore Art Museum.